# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ....០៧១.......ន.គ.ស/ឈ.ត.សា.

ថ្ងៃព្រហស្បតិ៍ ៣រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០២២

## សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសបេក្ខជនចូលបម្រើការងារជាមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៅនិយ័តករគណនេយ្យនិងសវនកម្ម

**និយ័តករគណនេយ្យនិងសវនកម្ម** (ន.គ.ស.) នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** មានកត្តិយស សូមជូនដំណឹងដល់ និស្សិត និងសាធារណជនទូទៅ ជ្រាបថា **និយ័តករគណនេយ្យនិងសវនកម្ម** ត្រូវជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីបម្រើការងារនៅ **និយ័តករគណនេយ្យនិងសវនកម្ម** ចំនួន ១៥រូប ដែលនៅក្នុងនោះ **ជំនាញគណនេយ្យនិងសវនកម្ម ចំនួន ១២រូប , ជំនាញព័ត៌មានវិទ្យា ចំនួន ២រូប និង ជំនាញនីតិសាស្ត្រ ចំនួន ១រូប** ស្របតាមលក្ខខណ្ឌនៃការជ្រើសរើស ដូចខាងក្រោម÷

### ១.លក្ខខណ្ឌនៃការជ្រើសរើស

#### ក.លក្ខខណ្ឌទូទៅ

- ត្រូវមានសញ្ជាតិខ្មែរ
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ លើជំនាញនីមួយៗ
- ត្រូវមានចំណេះដឹងកុំព្យូទ័រ Microsoft office
- ចេះភាសាអង់គ្លេសអាចប្រើប្រាស់ជាផ្លូវការបាន
- ត្រូវមានអាយុមិនលើស ៣៥ឆ្នាំ ចំពោះបេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល និង ៤០ឆ្នាំ ចំពោះបេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូល គិតត្រឹមថ្ងៃដាក់ពាក្យ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងជំនាញយ៉ាងតិច ០១ឆ្នាំ ត្រូវបានលើកទឹកចិត្ត
- មានស្មារតីធ្វើការងារជាក្រុម
- មិនធ្លាប់មានទោសពីបទឧក្រិដ្ឋ និងបទមជ្ឈិមណាមួយ
- មានគំនិតឆ្នៃប្រឌិត អត្តចរិកស្លូតបូត ស្មោះត្រង់ អំណត់អត់ធន់ ឧស្សាហ៍ព្យាយាម និងមានការទទួលខុសត្រូវខ្ពស់ក្នុងការងារ។

#### ខ. លក្ខខណ្ឌជាក់លាក់

- ចំពោះបេក្ខជនដែលមាន សញ្ញាបត្រគណនេយ្យករជំនាញ (CPA) ឬសញ្ញាបត្របច្ចេកទេសគណនេយ្យ (CAT) ត្រូវបានលើកទឹកចិត្ត សម្រាប់ជំនាញគណនេយ្យនិងសវនកម្ម
- ចំពោះបេក្ខជនដែលមានបំណងបម្រើការងារផ្នែកព័ត៌មានវិទ្យាសូមមើលនៅក្នុងភារកិច្ច និងទំនួលខុសត្រូវសំខាន់ៗតាមជំនាញនីមួយៗ ដែលបានភ្ជាប់មកជាមួយសេចក្តីជូនដំណឹងនេះ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ ០៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111

**គ. ឯកសារភ្ជាប់**

- សញ្ញាបត្រថតចម្លងដោយមានការបញ្ជាក់ជាផ្លូវការពីអាជ្ញាធរមានសមត្ថកិច្ច
- អត្តសញ្ញាណប័ណ្ណ ឬច្បាប់ចម្លងសំបុត្រកំណើត ឬ សៀវភៅគ្រួសារ(បញ្ជាក់ត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច)
- លិខិតថ្កោលទោសដែលនៅមានសុពលភាព (ក្រោយជាប់ជាស្ថាពរ)
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារចេញដោយនិយោជក។

**២.ការជ្រើសរើស**

ការជ្រើសរើសត្រូវធ្វើឡើងតាមរយៈការធ្វើតេស្តសមត្ថភាពលើវិញ្ញាសាសរសេរ និងការធ្វើសំភាសន៍ផ្ទាល់មាត់ពីគណៈកម្មាធិការជ្រើសរើស។

**៣.ការដាក់ពាក្យស្នើសុំជ្រើសរើស**

បេក្ខជនត្រូវចូលទៅកាន់តំណភ្ជាប់÷ http://recruit.acar.gov.kh ឬស្កេនលើ (QR code) ដើម្បីទាញយកពាក្យ និងដាក់ពាក្យប្រឡង ព្រមទាំងបំពេញបែបបទផ្សេងៗ។ **និយ័តករគណនេយ្យនិងសវនកម្ម** ទទួលពាក្យស្នើសុំចុះឈ្មោះរបស់បេក្ខជនឱ្យប្រឡងចូលបម្រើការងារនៅនិយ័តករគណនេយ្យនិងសវនកម្ម តាមប្រព័ន្ធអនឡាញ (online) តែប៉ុណ្ណោះ។

ការទទួលពាក្យចាប់ផ្តើមពីថ្ងៃជូនដំណឹងនេះតទៅរហូតដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង១៧:០០នាទីរសៀល ដោយឡែក កាលបរិច្ឆេទនៃការបង្ហាញខ្លួន និងកាលបរិច្ឆេទប្រឡង នឹងជូនដំណឹងនៅពេលក្រោយ។

*មានតែបេក្ខជនដែលត្រូវបានជាប់ជម្រុះ (shortlist) ប៉ុណ្ណោះ ដែលអាចចូលរួមធ្វើតេស្តលើវិញ្ញាសាសរសេរបាន និងមានតែបេក្ខជនដែលប្រឡងជាប់លើវិញ្ញាសាសរសេរប៉ុណ្ណោះ ទើបអាចចូលរួមធ្វើតេស្តសមត្ថភាពលើការសម្ភាសន៍ផ្ទាល់មាត់បាន។*

សម្រាប់ព័ត៌មានបន្ថែម ឬជំនួយបច្ចេកទេសផ្សេងៗ សូមទាក់ទងមកកាន់ **និយ័តករគណនេយ្យនិងសវនកម្ម** តាមរយៈលេខទូរស័ព្ទ ០២៣ ៨៨២ ១១១, ០១០ ៤២១ ៦៤៤, ០៩២ ២៥០ ៧១២ ឬមើលព័ត៌មាននៅក្នុងគេហទំព័រ https://www.acar.gov.kh/ ឬ Telegram Channel: https://t.me/acarstaffrecruitment។

អាសយដ្ឋាន **និយ័តករគណនេយ្យនិងសវនកម្ម** ÷ អគារ "ក" ជាន់ទី១ ទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**និយ័តករគណនេយ្យនិងសវនកម្ម**

បេក្ខជនអាចស្កេនលើ (QR code) ដើម្បីដាក់ពាក្យប្រឡងនិងបំពេញបែបបទផ្សេងៗ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម

# អ្នកជំនាញក្រាហ្វិកឌីសាញ និងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ
# GRAPHIC DESIGN AND MEDIA MANAGEMENT

## ១. ភារកិច្ច និងការទទួលខុសត្រូវសំខាន់ៗ

អ្នកជំនាញឌីសាញ និងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយមានភារកិច្ចឌីសាញ ផ្ទាំងផ្សព្វផ្សាយ (Poster), Backdrop, Leaflet, បង្កើតវីដេអូផ្សព្វផ្សាយផ្សេងៗ, គ្រប់គ្រង និងរៀបចំការ Livestream នៅលើ Facebook, YouTube និងគ្រប់គ្រងបណ្ដាញផ្សព្វផ្សាយនានារបស់ ន.គ.ស.។

**ការទទួលខុសត្រូវសំខាន់ៗមានដូចខាងក្រោម÷**

- សិក្សារៀបចំផែនការក្នុងការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយរបស់ ន.គ.ស. ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់
- ឌីសាញ ផ្ទាំងផ្សព្វផ្សាយនានា របស់ ន.គ.ស. ឱ្យមានភាពទាក់ទាញ និងប្រកបដោយភាពច្នៃប្រឌិត
- បង្កើតវីដេអូផ្សព្វផ្សាយផ្សេងៗដូចជា÷ វីដេអូផ្សព្វផ្សាយពីស្ថាប័ន, វីដេអូផ្សព្វផ្សាយពីច្បាប់ស្ដីគណនេយ្យ និងសវនកម្មនៅកម្ពុជា, វីដេអូផ្សព្វផ្សាយពីកាតព្វកិច្ចគណនេយ្យ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗសម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ, វីដេអូណែនាំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសេវាសាធារណៈរបស់ ន.គ.ស. និងវីដេអូផ្សព្វផ្សាយផ្សេងៗទៀតរបស់ ន.គ.ស.
- សិក្សារៀបចំផែនការក្នុងការផ្សព្វផ្សាយ ឬបង្កើតកម្មវិធីផ្សព្វផ្សាយផ្សេងៗ (Livestream) នៅលើបណ្ដាញសង្គម
- ថតរូបនៅរាល់កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗរបស់ ន.គ.ស. រួចផ្សព្វផ្សាយនៅលើបណ្ដាញសង្គម
- សិក្សាអំពីបច្ចេកវិទ្យាថ្មីៗ និងលើកជាគំនិតក្នុងការឌីសាញឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងស្របតាមឧត្តមានុវត្តន៍
- សហការជាមួយក្រុមការងារពាក់ព័ន្ធ ដើម្បីអនុវត្តការងារឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់
- អនុវត្តការងារផ្សេងទៀតដែលថ្នាក់ដឹកនាំបានប្រគល់ជូន

## ២. សមត្ថភាពក្នុងការបំពេញការងារ

- កម្រិតវប្បធម៌ចាប់ពីថ្នាក់បរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ ផ្នែកក្រាហ្វិកឌីសាញ ឬជំនាញពាក់ព័ន្ធផ្នែកក្រាហ្វិកឌីសសាញ
- មានបទពិសោធន៍ការងារពាក់ព័ន្ធផ្នែកក្រាហ្វិកឌីសាញ និងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយយ៉ាងតិច ២ ឆ្នាំ
- មានបទពិសោធន៍ក្នុងការឌីសាញដោយប្រើប្រាស់កម្មវិធីដូចជា÷ Adobe Photoshop, Adobe Illustrator
- មានបទពិសោធន៍ក្នុងការបង្កើតវីដេអូផ្សព្វផ្សាយដោយប្រើប្រាស់កម្មវិធីដូចជា÷ Adobe Premiere Pro, Adobe After Effects ឬកម្មវិធីផ្សេងទៀត
- មានបទពិសោធន៍ក្នុងការបង្កើតការ Livestream នៅលើបណ្ដាញសង្គមផ្សេងៗដូចជា Facebook, YouTube ដោយប្រើប្រាស់កម្មវិធី OBS ឬ Stream labs ជាដើម
- មានបទពិសោធន៍ក្នុងការប្រើប្រាស់ Cinema 4D កាន់តែប្រសើរ
- មានភាពជាអ្នកដឹកនាំ ភាពស្ទាត់ជំនាញ និងច្នៃប្រឌិតក្នុងការវិភាគ និងដោះស្រាយបញ្ហាជំនាញ ធ្វើផែនការចាត់ចែងនិងគ្រប់គ្រងពេលវេលាព្រមទាំងមានគំនិតផ្តួចផ្តើមនិងភាពអំណត់ខ្ពស់
- មានសមត្ថភាពទំនាក់ទំនងដោយផ្ទាល់មាត់ និងសរសេរជាលាយលក្ខណ៍អក្សរជាភាសាខ្មែរ និងភាសាអង់គ្លេស អំពីព័ត៌មានបច្ចេកទេសលម្អិតស្តីពីការដោះស្រាយបញ្ហានិងការខិតខំប្រឹងប្រែងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ ០២៣ ៨៨២ ១១១
Phone: 023 882 111

## អ្នកជំនាញអភិវឌ្ឍប្រព័ន្ធ
## SOFTWARE DEVELOPER

### ១. ភារកិច្ច និងការទទួលខុសត្រូវសំខាន់ៗ

អ្នកជំនាញអភិវឌ្ឍន៍ប្រព័ន្ធមានភារកិច្ចអភិវឌ្ឍប្រព័ន្ធ ថែទាំ ធ្វើទំនើបកម្ម និងបន្តអភិវឌ្ឍមុខងារបន្ថែមនៅលើប្រព័ន្ធរបស់ ធ.ត.ស. ដែលមានស្រាប់។

**ការទទួលខុសត្រូវសំខាន់ៗមានដូចខាងក្រោម÷**

- សិក្សារៀបចំ អភិវឌ្ឍ និងថែទាំប្រព័ន្ធគ្រប់គ្រងសេវាសាធារណៈរបស់ ធ.ត.ស.
- ធ្វើតេស្ត និងវាយតម្លៃលើការអភិវឌ្ឍប្រព័ន្ធ
- អភិវឌ្ឍប្រព័ន្ធស្របទៅតាមស្តង់ដារ នៃការអភិវឌ្ឍប្រព័ន្ធ
- សិក្សាអំពីបច្ចេកវិទ្យាថ្មីៗ និងផ្តល់យោបល់លើការអភិវឌ្ឍប្រព័ន្ធកាន់តែមានប្រសិទ្ធភាពខ្ពស់ សុវត្ថិភាព និងងាយស្រួលក្នុងការគ្រប់គ្រង និងថែទាំ
- បង្កើនគុណភាពប្រព័ន្ធ ដោយកំណត់ ដោះស្រាយបញ្ហានិងកែប្រែចំណុចខ្វះខាតនានា
- បន្តអភិវឌ្ឍមុខងារបន្ថែមនៅលើប្រព័ន្ធរបស់ ធ.ត.ស. ដែលមានស្រាប់
- ដោះស្រាយរាល់បញ្ហាបច្ចេកទេសផ្សេងៗ ដែលមាននៅលើប្រព័ន្ធ
- សហការជាមួយក្រុមការងារពាក់ព័ន្ធដើម្បីអនុវត្តការងារអភិវឌ្ឍប្រព័ន្ធឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ទាន់ពេលវេលា
- អនុវត្តការងារផ្សេងទៀតដែលថ្នាក់ដឹកនាំបានប្រគល់ជូន

### ២. សមត្ថភាពក្នុងការបំពេញការងារ

- កម្រិតវប្បធម៌ចាប់ពីថ្នាក់បរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ ផ្នែកបច្ចេកវិទ្យាពត៌មាន ឬជំនាញពាក់ព័ន្ធបច្ចេកវិទ្យាពត៌មាន
- មានបទពិសោធន៍ការងារពាក់ព័ន្ធបច្ចេកវិទ្យាពត៌មានយ៉ាងតិច ០២ ឆ្នាំ ទាក់ទងនឹងការអភិវឌ្ឍប្រព័ន្ធ ដោយប្រើប្រាស់ភាសាកូដដូចជា÷ HTML, CSS, JavaScript, jQuery, SASS, Bootstrap, Material UI, React.JS, ASP.Net Core, SQL Server
- មានបទពិសោធន៍ក្នុងការអភិវឌ្ឍប្រព័ន្ធដោយប្រើប្រាស់ RESTful API
- មានបទពិសោធន៍គ្រប់គ្រងគម្រោងបច្ចេកវិទ្យាពត៌មានពាក់ព័ន្ធនឹងវដ្តនៃការអភិឌ្ឍប្រព័ន្ធ
- មានបទពិសោធន៍ក្នុងការ Deploy ប្រព័ន្ធដាក់ឱ្យប្រើប្រាស់
- មានបទពិសោធន៍អភិវឌ្ឍកម្មវិធីទូរស័ព្ទឆ្លាតវៃ កាន់តែប្រសើរ
- មានវិញ្ញាបនបត្រ Certified Software Developer កាន់តែប្រសើរ
- មានភាពជាអ្នកដឹកនាំ ភាពស្ទាត់ជំនាញ និងឆ្នៃប្រឌិតក្នុងការវិភាគនិងដោះស្រាយបញ្ហា ជំនាញធ្វើផែនការចាត់ចែងនិងគ្រប់គ្រងពេលវេលា ព្រមទាំងមានគំនិតផ្តួចផ្តើមនិងភាពអំណត់ខ្ពស់
- មានសមត្ថភាពទំនាក់ទំនងដោយផ្ទាល់មាត់ និងសរសេរជាលាយលក្ខណ៍អក្សរជាភាសាខ្មែរ និងភាសាអង់គ្លេសអំពីព័ត៌មានបច្ចេកទេសលម្អិតស្តីពីការដោះស្រាយបញ្ហានិងការខិតខំប្រឹងប្រែងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។